**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :.........៤៣៨...............ក.ប/វ.ល**

# ជំនួយស្មារតី

## អំពីបច្ចុប្បន្នភាពលទ្ធផលនៃការអនុវត្ត
## អនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ៩ ចំណុច របស់សម្តេចតេជោនាយករដ្ឋមន្ត្រី

ស្ថានភាពកម្លាំងពលកម្ម

ឆ្នាំ២០១៨ នេះ វិស័យការងារបន្តអភិវឌ្ឍរីកចម្រើន អត្រាមានការងារធ្វើ ៩៩,៣%, បរិមាណការងារសរុបមានប្រមាណជិត ១០លាននាក់។ សហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនសរុបជាង ១ម៉ឺន ២ពាន់ គ្រឹះស្ថាន កើនចំនួន១០,០២% និងមានកម្មករនិយោជិតសរុបចំនួនជិត១លាន ៥សែននាក់ កើនចំនួន ២១,១១% (ស្រីជាង៨សែននាក់) ធៀបនឹងឆ្នាំ២០១៧។ សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានចំនួនជិត៦សែន មានកម្មករចំនួនជាង ២លាន ៤សែននាក់ វិស័យកសិកម្មប្រមាណជាង ៤លាននាក់, ពលករធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណ ១លាន ២សែននាក់ និងមន្ត្រីសាធារណៈចំនួនប្រមាណជាង ៥សែននាក់។

ទី១-គ្រប់រោងចក្រទាំងអស់បានអនុវត្តប្រាក់ឈ្នួលអប្បបរមា ១៧០ដុល្លារ សម្រាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង។

| កម្ពុជា | បង់ក្លាដេស | ស្រីលង្កា | ឥណ្ឌា | មីយ៉ាន់ម៉ា | ឥណ្ឌូនេស៊ី | វៀតណាម | ឡាវ | ប៉ាគីស្ថាន |
|---|---|---|---|---|---|---|---|---|
| ១៧០ដុល្លារ | ៦៧ដុល្លារ | ៦៧ដុល្លារ | ៧៧ដុល្លារ ដល់ ១៤៣ដុល្លារ | ១០៨ដុល្លារ | ១០៧ដុល្លារ ដល់ ២៦៧ដុល្លារ | ១២២ដុល្លារ ដល់ ១៧៥ដុល្លារ | ១៣៣ដុល្លារ | ១៣៤ដុល្លារ |

ទី២-បានអនុវត្តកម្មវិធីផ្តល់ការពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់ ដោយមិនបង់ប្រាក់បានចំនួនជាង ២សែន ៦ម៉ឺននាក់ ត្រូវជាជាង ៧សែន ដងនាក់ ចំណាយថវិកាចំនួន ៤៧,៧ ប៊ីលានរៀល។

ទី៣-បានផ្តល់ប្រាក់ឈ្នួល ១២០ភាគរយ និងការឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូន ដល់កម្មការិនីចំនួនជិត៧ពាន់នាក់ ដោយផ្តល់ថវិកាអស់ចំនួន ១៣,០១ ប៊ីលានរៀល។

ទី៤-បានអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន គិតចាប់ពីថ្ងៃទី០១ មករា ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០១៨ មានកម្មការិនីសម្រាលកូនចំនួន ១២.៥១១នាក់ ចំនួនកូន ១២.៦០០នាក់ ដែលបានផ្តល់ប្រាក់ឧបត្ថម្ភសរុបចំនួន៥០ពាន់លានរៀល។

ទី៥-បេឡាជាតិរបបសន្តិសុខសង្គម បានកំណត់ឱ្យនិយោជកជាប់កាតព្វកិច្ចបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព១០០% ជំនួសកម្មករនិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨ មានចំនួនជិត ៧ពាន់ សហគ្រាស ដែលមានកម្មករនិយោជិតជាង ១លាន ៣សែននាក់។

ដែលប្រព័ន្ធអគ្គិសនី និងទឹកស្អាតរបស់រដ្ឋទៅដល់បានអនុវត្តតាមការកំណត់។ ប៉ុន្តែនៅសល់តំបន់មួយចំនួនដែលប្រព័ន្ធអគ្គិសនី និងទឹកស្អាតរបស់រដ្ឋមិនទាន់ដល់ នៅមានតម្លៃខ្ពស់ជាង។

ទី៧-បេឡាជាតិរបបសន្តិសុខសង្គម កំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តិដើម្បីដាក់ឲ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍ឆ្នាំ២០១៩ ពិសេសកំពុងរៀបចំវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គម ការសិក្សាផ្នែកបច្ចេកទេស និងយន្តការសម្រាប់អនុវត្តចប់សព្វគ្រប់នៅឆ្នាំ២០១៨។

ទី៨-បានផ្តល់បុរេប្រទានថវិកាចំនួនជាង ៤លាន ៦សែនដុល្លារ សម្រាប់ទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតចំនួន ៤,១៤៦នាក់ នៅរោងចក្រចំនួន៩ ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដែលបិទទ្វារដោយម្ចាស់រត់ចោល។

ទី៩-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏កំពុងយកចិត្តទុកដាក់ដល់ពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ដោយបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូរួមមាន៖ ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សឹង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីបន្តផ្តល់ឱកាសការងារជូនពលករ ការពារសិទ្ធិ ផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណៈសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គម ទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

ថ្ងៃ សុក្រ ៧កើត ខែ ចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ២០១៨

រដ្ឋមន្ត្រី

**អ៊ិត សំហេង**